# កិច្ចព្រមព្រៀង

រវាង

រាជរដ្ឋាភិបាលកម្ពុជា

និង

រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

ស្តីពី

កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ

ឆ្នាំ ២០១៥-២០១៦

## រាជរដ្ឋាភិបាលកម្ពុជា
## និង
## រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

ក្នុងស្មារតីនៃទំនាក់ទំនងមិត្តភាពរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

ក្នុងបំណងពង្រឹង និងរឹតចំណងទំនាក់ទំនងមិត្តភាព តាមរយៈកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុ ក្នុងស្មារតីនៃភាពជាដៃគូ

ដោយយល់ថា ការថែរក្សាទំនាក់ទំនងនេះគឺជាមូលដ្ឋានគ្រឹះនៃកិច្ចព្រមព្រៀងនេះ

ក្នុងគោលបំណងរួមចំណែកការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា

យោងរបាយការណ៍សង្ខេប ស្តីពីកិច្ចចរចាអន្តររដ្ឋាភិបាល នាថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ នៅទីក្រុងប៊ែរឡាំង

បានព្រមព្រៀងដូចខាងក្រោម ÷

### មាត្រា ១

១- រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នឹងផ្តល់ជូនរាជរដ្ឋាភិបាលកម្ពុជាតាមរយៈសាជីវកម្មឥណទាននីតិសម្បទា (Reconstruction Loan Corporation – KfW) នូវវិភាគទានហិរញ្ញវត្ថុសរុប ២២.១០០.០០០ អឺរ៉ូ (ម្ភៃពីរលានមួយរយពាន់អឺរ៉ូ) សម្រាប់គម្រោងដូចខាងក្រោម ÷

ក- កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ- ដំណាក់កាលទី ៥ ដែលមានហិរញ្ញប្បទានរហូតដល់ ៩.០០០.០០០ អឺរ៉ូ (ប្រាំបួនលានអឺរ៉ូ)

ខ- កម្មវិធីហេដ្ឋារចនាសម្ព័ន្ធជនបទ- ដំណាក់កាលទី ៦ ដែលមានហិរញ្ញប្បទានរហូតដល់ ៥.១០០.០០០ អឺរ៉ូ (ប្រាំលានមួយរយពាន់អឺរ៉ូ)

គ- វិភាគទានហិរញ្ញវត្ថុរបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ សម្រាប់កម្មវិធីកែលម្អគុណភាព និងសមធម៌សុខភាព ដែលមានហិរញ្ញប្បទានរហូតដល់ ៦.០០០.០០០ អឺរ៉ូ (ប្រាំមួយលានអឺរ៉ូ)

ឃ-វិធានការគាំទ្រសម្រាប់វិភាគទានហិរញ្ញវត្ថុរបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ក្នុងកម្មវិធីកែលម្អគុណភាព និងសមធមិសុខភាព ដែលមានហិរញ្ញប្បទានរហូតដល់ ២.០០០.០០០ អឺរ៉ូ (ពីរលានអឺរ៉ូ)

ប្រសិនបើពិនិត្យឃើញថា គម្រោងទាំងនេះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់គាំទ្រ ។

២- គម្រោងទាំងឡាយដែលមានចែងក្នុងកថាខណ្ឌ ១ ខាងលើ អាចជំនួសដោយគម្រោងផ្សេងទៀតបាន លុះត្រាតែមានការឯកភាពរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ។

៣- កិច្ចព្រមព្រៀងនេះក៏មានវិសាលភាពគ្របដណ្តប់ផងដែរ ប្រសិនបើនៅថ្ងៃក្រោយ រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់អាចផ្តល់វិភាគទានហិរញ្ញវត្ថុបន្ថែម ជូនរាជរដ្ឋាភិបាលកម្ពុជា តាមរយៈ KfW សម្រាប់រៀបចំគម្រោងដែលមានចែងក្នុងកថាខណ្ឌ ១ ខាងលើ ឬសម្រាប់ផ្តល់ចំណាត់ការចាំបាច់នានា ដើម្បីអនុវត្ត និងគាំទ្រគម្រោងដែលមានចែងក្នុងកថាខណ្ឌ ១ ខាងលើ ។

## មាត្រា ២

១- ការប្រើប្រាស់ហិរញ្ញប្បទានដែលមានចែងក្នុងមាត្រា ១.១ នៃកិច្ចព្រមព្រៀងនេះ និងលក្ខខណ្ឌ ព្រមទាំងនីតិវិធីនៃការផ្តល់កិច្ចសន្យា ត្រូវគ្រប់គ្រងដោយកិច្ចព្រមព្រៀងដែលនឹងត្រូវចុះហត្ថលេខារវាង KfW និងអ្នកទទួលវិភាគទានហិរញ្ញវត្ថុ ហើយត្រូវស្ថិតនៅក្រោមអំណាចនៃច្បាប់ និងលិខិតបទដ្ឋាននានារបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ។

២- ការសន្យាផ្តល់ហិរញ្ញប្បទានឥតសំណងដែលមានចែងក្នុងមាត្រា ១.១ នៃកិច្ចព្រមព្រៀងនេះ នឹងត្រូវអស់សុពលភាព ប្រសិនបើកិច្ចព្រមព្រៀងហិរញ្ញប្បទានពាក់ព័ន្ធ មិនត្រូវបានចុះហត្ថលេខាក្នុងរយៈពេល ៧ ឆ្នាំ បន្ទាប់ពីឆ្នាំនៃការសន្យាត្រូវបានប្រកាសឡើង ។ វិភាគទានហិរញ្ញវត្ថុនេះមានសុពលភាពត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២២ ។

៣- រាជរដ្ឋាភិបាលកម្ពុជា ក្នុងករណីមិនមែនជាអ្នកទទួលវិភាគទានហិរញ្ញវត្ថុនេះដោយផ្ទាល់ ត្រូវធានាការសងប្រាក់ទាន់ពេលកំណត់ទៅឱ្យ KfW វិញ ដោយផ្អែកលើកិច្ចសន្យាហិរញ្ញប្បទានដែលនឹងត្រូវបានចុះហត្ថលេខាស្របតាមកថាខណ្ឌ ១ ខាងលើ ។

**មាត្រា ៣**

រាជរដ្ឋាភិបាលកម្ពុជាត្រូវបង់ជំនួស KfW នូវពន្ធ និងអាករជាបន្ទុករបស់រដ្ឋ ព្រមទាំងថ្លៃសេវាសាធារណៈផ្សេងទៀតក្នុងព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធនឹងការសម្រេចកិច្ចសន្យា និងការអនុវត្តកិច្ចសន្យា ដូចមានចែងក្នុងមាត្រា ២.១ នៃកិច្ចព្រមព្រៀងនេះ ។

**មាត្រា ៤**

រាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុញ្ញាតឱ្យអ្នកធ្វើដំណើរ និងអ្នកផ្គត់ផ្គង់ អាចជ្រើសរើសដោយសេរីនូវសហគ្រាសដឹកជញ្ជូន សម្រាប់ការដឹកជញ្ជូនមនុស្ស និងទំនិញតាមសមុទ្រ តាមផ្លូវគោក ឬតាមអាកាស ក្នុងក្របខណ្ឌនៃការផ្តល់វិភាគទានហិរញ្ញវត្ថុនេះ ហើយចៀសវាងការដាក់វិធានការណាមួយដែលអាចរារាំងការចូលរួម ឬបង្កការលំបាកដល់ការចូលរួមដោយស្មើភាពរបស់សហគ្រាសដឹកជញ្ជូន ដែលមានទីតាំងធុរៈកិច្ចនៅក្នុងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ព្រមទាំងផ្តល់ការអនុញ្ញាតចាំបាច់នានា សម្រាប់ការចូលរួមរបស់សហគ្រាសទាំងនោះ ។

**មាត្រា ៥**

១- ហិរញ្ញប្បទានចំនួន ៦.០០០.០០០ អឺរ៉ូ (ប្រាំមួយលានអឺរ៉ូ ) ដែលជាវិភាគទានហិរញ្ញវត្ថុសម្រាប់គម្រោងរបស់អាល្លឺម៉ង់ក្នុងកម្មវិធីគាំទ្រវិស័យសុខាភិបាលនៅកម្ពុជា ដែលមានចែងក្នុងកិច្ចព្រមព្រៀង នាថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៤ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ស្តីពីកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុឆ្នាំ ២០១៣ ហើយដែលត្រូវបានធ្វើវិសោធនកម្មតាមកិច្ចព្រមព្រៀង នាថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ និងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១៤ ត្រូវផ្ទេរមកប្រើប្រាស់ក្នុងកម្មវិធីកែលម្អគុណភាព និងសមធម៌សុខភាព ដូចមានចែងក្នុងមាត្រា ១.១.គ នៃកិច្ចព្រមព្រៀងនេះ ប្រសិនបើពិនិត្យឃើញថា កម្មវិធីនេះមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់គាំទ្រ ។

២- វិភាគទានហិរញ្ញវត្ថុនេះមានសុពលភាពត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ ។

## មាត្រា ៦

១- កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

២- យោងតាមមាត្រា ១០២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នឹងចុះបញ្ជីនៃកិច្ចព្រមព្រៀងនេះ នៅលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ បន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន ។ ភាគីហត្ថលេខីម្ខាងទៀត នឹងទទួលព័ត៌មានពីការចុះបញ្ជីនៅអង្គការសហប្រជាជាតិ និងលេខចុះបញ្ជីនេះ បន្ទាប់ពីមានការបញ្ជាក់ពីលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ ជាភាសាខ្មែរ, អាល្លឺម៉ង់ និងអង់គ្លេស ។ អត្ថបទទាំង ៣ ភាសានេះមានតម្លៃដូចគ្នា ។ ក្នុងករណីមានការបកស្រាយមិនស្របគ្នារវាងអត្ថបទភាសាអាល្លឺម៉ង់ និងភាសាខ្មែរ នោះ អត្ថបទភាសាអង់គ្លេស នឹងត្រូវទុកជាបានការ ។

**តំណាងរាជរដ្ឋាភិបាលកម្ពុជា**

**គាត ឈន់**

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**អនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**តំណាងរដ្ឋាភិបាល**

**សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់**

**Joachim Baron Marschall von Bieberstein**

**ឯកអគ្គរដ្ឋទូត**

**សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំកម្ពុជា**

# កិច្ចព្រមព្រៀង

រវាង

រាជរដ្ឋាភិបាលកម្ពុជា

និង

រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

ស្តីពី

កិច្ចសហប្រតិបត្តិការបច្ចេកទេស

ឆ្នាំ ២០១៥ - ២០១៦

# រាជរដ្ឋាភិបាលកម្ពុជា
# និង
# រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

ក្នុងស្មារតីនៃទំនាក់ទំនងមិត្តភាពរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

ក្នុងបំណងពង្រឹង និងរឹតចំណងទំនាក់ទំនងមិត្តភាព តាមរយៈកិច្ចសហប្រតិបត្តិការបច្ចេកទេស ក្នុងស្មារតីនៃភាពជាដៃគូ

ដោយយល់ថា ការថែរក្សាទំនាក់ទំនងនេះគឺជាមូលដ្ឋានគ្រឹះនៃកិច្ចព្រមព្រៀងនេះ

ក្នុងគោលបំណងរួមចំណែកការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា

យោងរបាយការណ៍សង្ខេប ស្តីពីកិច្ចចរចាអន្តររដ្ឋាភិបាល នាថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ នៅទីក្រុងប៊ែរឡាំង

និងអនុលោមតាមកិច្ចព្រមព្រៀង នាថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៤

បានព្រមព្រៀងដូចខាងក្រោម ៖

## មាត្រា ១

១- អនុលោមតាមកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស ដែលត្រូវបានចុះហត្ថលេខានាថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៤ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ គម្រោងដូចមានចែងខាងក្រោម ត្រូវបានទទួលការគាំទ្រ ៖

ក- ការកែទម្រង់វិមជ្ឈការ និងរដ្ឋបាល- ដំណាក់កាលទី ៥

ខ- កម្មវិធីស្តីពីការគាំពារសុខភាពសង្គម- ដំណាក់កាលទី ៣

គ- ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ- ដំណាក់កាលទី ៥

ឃ- កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន- ដំណាក់កាលទី ៤

ង- មូលនិធិសម្រាប់ការសិក្សា និងជំនាញការ

ប្រសិនបើពិនិត្យឃើញថា គម្រោងទាំងនេះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់គាំទ្រ ។

២- សម្រាប់គម្រោងដែលមានចែងក្នុងកថាខណ្ឌ ១ ខាងលើ រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នឹងផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការសរុបរបស់ខ្លួន ចំនួន ១៤.៦៤០.០០០ អឺរ៉ូ (ដប់បួនលានប្រាំមួយរយសែសិបពាន់អឺរ៉ូ) ក្រោមទម្រង់ជាការផ្តល់បុគ្គលិក, ធាតុចូល និងការផ្តល់ហិរញ្ញប្បទានសមស្រប ។ Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH ទទួលបន្ទុកអនុវត្តគម្រោងដែលមានចែងក្នុងកថាខណ្ឌ ១.ក ដល់ ១.ង ខាងលើ ។

៣- រាជរដ្ឋាភិបាលកម្ពុជាត្រូវធានាថា គម្រោងនីមួយៗមានខ្ទង់ថវិកាផ្ទាល់ ដើម្បីធានាភាពរលូនក្នុងការអនុវត្ត ហើយស្ថាប័នទទួលបន្ទុកអនុវត្តផ្តល់ការគាំទ្រចាំបាច់សម្រាប់គម្រោងដែលមានចែងក្នុងកថាខណ្ឌ ១ ខាងលើ ។

៤- គម្រោងទាំងឡាយដែលមានចែងក្នុងកថាខណ្ឌ ១ ខាងលើ អាចជំនួសដោយគម្រោងផ្សេងទៀតបាន លុះត្រាតែមានការឯកភាពរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ។

៥- ការសន្យាសម្រាប់គម្រោងដែលមានចែងក្នុងកថាខណ្ឌ ១ ខាងលើ និងការសន្យាផ្តល់ហិរញ្ញប្បទានសម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេសដែលមានចែងនៅក្នុងកថាខណ្ឌ ២ ខាងលើ នឹងត្រូវអស់សុពលភាព ដោយគ្មានការជំនួសអ្វីទាំងអស់ ប្រសិនបើកិច្ចព្រមព្រៀងអនុវត្ត និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ដូចមានចែងក្នុងមាត្រា ២ នៃកិច្ចព្រមព្រៀងនេះ មិនត្រូវបានអនុវត្តក្នុងរយៈពេល ៧ ឆ្នាំ បន្ទាប់ពីឆ្នាំដែលការសន្យាបានប្រកាសឡើង ។ ដោយមិនប៉ះពាល់ដល់ខ្លឹមសារដែលមានចែងក្នុងកថាខណ្ឌ ៤ ខាងលើ កាលបរិច្ឆេទផុតសុពលភាពនៃការសន្យាដែលប្រកាសឡើងក្នុងឆ្នាំនេះ គឺថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២២ ។ ក្នុងរយៈពេលសុពលភាពនេះ ប្រសិនបើកិច្ចព្រមព្រៀងអនុវត្ត និងកិច្ចព្រមព្រៀងហិរញ្ញប្បទានត្រូវអនុវត្តបានត្រឹមតែមួយផ្នែកនៃការសន្យា ការលុបចោលនឹងត្រូវអនុវត្តចំពោះធនធានដែលនៅសេសសល់ក្រៅពីកិច្ចព្រមព្រៀងទាំងនេះ ។

## មាត្រា ២

ខ្លឹមសារលម្អិតនៃគម្រោងដែលមានចែងក្នុងមាត្រា ១.១ នៃកិច្ចព្រមព្រៀងនេះ និងវិភាគទាន ព្រមទាំងកាតព្វកិច្ចនានា នឹងត្រូវចែងក្នុងកិច្ចព្រមព្រៀងអនុវត្ត និងកិច្ចព្រមព្រៀងហិរញ្ញប្បទានដោយឡែកដែលនឹងត្រូវកំណត់ដោយស្ថាប័នទទួលបន្ទុកអនុវត្ត ដូចមានចែងក្នុងមាត្រា ១.២ និង ១.៣ នៃកិច្ចព្រមព្រៀងនេះ ។ កិច្ចព្រមព្រៀងអនុវត្តគម្រោង និងកិច្ចព្រមព្រៀងហិរញ្ញប្បទានទាំងនេះ ត្រូវស្ថិតនៅក្រោមអំណាចនៃច្បាប់ និងលិខិតបទដ្ឋាននានារបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ។

## មាត្រា ៣

១- រាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកបង់ពន្ធលើសម្ភារៈបរិក្ខារ, យានយន្ត និងគ្រឿងបន្លាស់នាំចូលសម្រាប់អនុវត្តគម្រោងដែលមានចែងក្នុងមាត្រា ១.១ នៃកិច្ចព្រមព្រៀងនេះ និងត្រូវចំណាយជំនួសឱ្យរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ លើអាជ្ញាប័ណ្ណ, ពន្ធគយ, ថ្លៃឈ្នួលចូលចត, ពន្ធនាំចូល, ពន្ធនាំចេញ និងថ្លៃសេវាសាធារណៈដទៃទៀត រួមទាំងថ្លៃឈ្នួលឃ្លាំង ហើយត្រូវធានាថាការបំពេញបែបបទគយត្រូវដំណើរការដោយគ្មានការយឺតយ៉ាវ ។

២- រាជរដ្ឋាភិបាលកម្ពុជាត្រូវធានាបង់ពន្ធ និងអាករជាបន្ទុករបស់រដ្ឋ នូវថ្លៃសេវាសាធារណៈទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជំនួសឱ្យ GIZ ដែលពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងអនុវត្ត និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ដូចមានចែងនៅក្នុងមាត្រា ២ នៃកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៤

ក្នុងទិដ្ឋភាពដទៃទៀត ខ្លឹមសារទាំងឡាយនៃកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស ដែលបានចុះហត្ថលេខានាថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៤ ហើយដែលមានចែងក្នុងមាត្រា ១.១ ខាងលើ នឹងត្រូវយកមកអនុវត្តចំពោះកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៥

កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១៦ ជាភាសាខ្មែរ, អាល្លឺម៉ង់ និងអង់គ្លេស ។ អត្ថបទទាំង ៣ ភាសានេះមានតម្លៃដូចគ្នា ។ ក្នុងករណីមានការបកស្រាយមិនស្របគ្នារវាងអត្ថបទភាសាអាល្លឺម៉ង់ និងភាសាខ្មែរ នោះអត្ថបទភាសាអង់គ្លេស នឹងត្រូវទុកជាបានការ ។

**តំណាងរាជរដ្ឋាភិបាលកម្ពុជា**

[signature]

**គាត ឈន់**

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**អនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**តំណាងរដ្ឋាភិបាល**

**សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់**

Joachim Freiherr Marschall von Bieberstein

**ឯកអគ្គរដ្ឋទូត**

**សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំកម្ពុជា**

កិច្ចព្រមព្រៀង

រវាង

រាជរដ្ឋាភិបាលកម្ពុជា

និង

រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

ស្តីពី

កិច្ចសហប្រតិបត្តិការបច្ចេកទេស

គំនិតផ្តួចផ្តើមពិសេស - ពិភពលោកមួយគ្មានភាពអត់ឃ្លាន

ឆ្នាំ ២០១៥

**រាជរដ្ឋាភិបាលកម្ពុជា**

**និង**

**រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់**

ក្នុងស្មារតីនៃទំនាក់ទំនងមិត្តភាពរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

ក្នុងបំណងពង្រឹង និងរឹតចំណងទំនាក់ទំនងមិត្តភាព តាមរយៈកិច្ចសហប្រតិបត្តិការបច្ចេកទេស ក្នុងស្មារតីនៃភាពជាដៃគូ

ដោយយល់ថា ការថែរក្សាទំនាក់ទំនងនេះគឺជាមូលដ្ឋានគ្រឹះនៃកិច្ចព្រមព្រៀងនេះ

ក្នុងគោលបំណងរួមចំណែកការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា

យោងការសន្យាផ្តល់ហិរញ្ញប្បទាន តាមកំណត់ទូតលេខ ៦១/១៥ នាថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ និង របាយការណ៍សង្ខេប ស្តីពីកិច្ចចរចាអន្តររដ្ឋាភិបាល នាថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ នៅទីក្រុងប៊ែរឡាំង

និងអនុលោមតាមកិច្ចព្រមព្រៀង នាថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៤

បានព្រមព្រៀងដូចខាងក្រោម ÷

**មាត្រា ១**

១- អនុលោមតាមកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស ដែលបានចុះហត្ថលេខា នាថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៤ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ គម្រោងដូចមានចែងខាងក្រោមនេះ ត្រូវបានទទួលការគាំទ្រ ÷

ក- គម្រោងពហុវិស័យស្តីពីសន្តិសុខស្បៀង និងអាហាររូបត្ថម្ភនៅកម្ពុជា (ក្រោមដំបូលនៃគំនិតផ្តួចផ្តើមពិសេសពិភពលោកមួយគ្មានភាពអត់ឃ្លាន)

ប្រសិនបើពិនិត្យឃើញថា គម្រោងនេះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់គាំទ្រ ។

២- ក្នុងក្របខណ្ឌនៃគំនិតផ្តួចផ្តើមពិសេស- ពិភពលោកមួយគ្មានភាពអត់ឃ្លាន រដ្ឋាភិបាលសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នឹងផ្តល់ហិរញ្ញប្បទានផ្ទាល់របស់ខ្លួន ចំនួន ៤.៨០០.០០០ អឺរ៉ូ (បួនលានប្រាំបីរយពាន់អឺរ៉ូ) ក្រោមទម្រង់ជាការផ្តល់បុគ្គលិក, ធាតុចូល និងវិភាគទានហិរញ្ញវត្ថុសមស្រប ដូចមានចែងក្នុងកថាខណ្ឌ ១ ខាងលើ ។ Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH ទទួលបន្ទុកអនុវត្តគម្រោងដូចមានចែងក្នុងកថាខណ្ឌ ១ ខាងលើ ។

៣- រាជរដ្ឋាភិបាលកម្ពុជា ត្រូវធានាថា គម្រោងនីមួយៗមានខ្ទង់ថវិកាផ្ទាល់ ដើម្បីធានាភាពរលូនក្នុងការអនុវត្ត និងត្រូវធានាថា ស្ថាប័នទទួលបន្ទុកអនុវត្តផ្តល់ការគាំទ្រចាំបាច់សម្រាប់គម្រោងដែលមានចែងក្នុងកថាខណ្ឌ ១ ខាងលើ ។

៤- គម្រោងទាំងឡាយដែលមានចែងក្នុងកថាខណ្ឌ ១ ខាងលើ មិនអាចជំនួសដោយគម្រោងផ្សេងបានឡើយ ។

៥- ការសន្យាសម្រាប់គម្រោងដែលមានចែងក្នុងកថាខណ្ឌ ១ ខាងលើ សម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេស ចំនួន ៣.៣០០.០០០ អឺរ៉ូ (បីលានបីរយពាន់អឺរ៉ូ) នឹងត្រូវអស់សុពលភាព ដោយគ្មានការជំនួសអ្វីទាំងអស់ ប្រសិនបើប្រើប្រាស់ហិរញ្ញប្បទាននេះមិនអស់ នាត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ ។ ហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស ចំនួន ១.៥០០.០០០ អឺរ៉ូ (មួយលានប្រាំរយពាន់អឺរ៉ូ) ទៀត នឹងត្រូវអស់សុពលភាព ដោយគ្មានការជំនួសអ្វីទាំងអស់ ប្រសិនបើប្រើប្រាស់ហិរញ្ញប្បទាននេះមិនអស់ នាត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ ។

## មាត្រា ២

ខ្លឹមសារលម្អិតនៃគម្រោងដែលមានចែងក្នុងមាត្រា ១.១ នៃកិច្ចព្រមព្រៀងនេះ និងវិភាគទាន ព្រមទាំងកាតព្វកិច្ចនានា នឹងត្រូវចែងក្នុងកិច្ចព្រមព្រៀងអនុវត្ត និងកិច្ចព្រមព្រៀងហិរញ្ញប្បទានដោយឡែកដែលនឹងត្រូវកំណត់ដោយស្ថាប័នទទួលបន្ទុកអនុវត្ត ដូចមានចែងក្នុងមាត្រា ១.២ និង ១.៣ នៃកិច្ចព្រមព្រៀងនេះ ។ កិច្ចព្រមព្រៀងអនុវត្តគម្រោង និងកិច្ចព្រមព្រៀងហិរញ្ញប្បទានទាំងនេះ ត្រូវស្ថិតនៅក្រោមអំណាចនៃច្បាប់ និងលិខិតបទដ្ឋាននានារបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ។

## មាត្រា ៣

១- រាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកបង់ពន្ធ នូវសម្ភារៈបរិក្ខារ, យានយន្ត និងគ្រឿងបន្លាស់នាំចូលសម្រាប់អនុវត្តគម្រោងដែលមានចែងក្នុងមាត្រា ១.១ នៃកិច្ចព្រមព្រៀងនេះ និងត្រូវចំណាយជំនួសឱ្យរដ្ឋាភិបាលសាធារណរដ្ឋ

សហពន្ធ័អាល្លឺម៉ង់លើអាជ្ញាប័ណ្ណ, ពន្ធគយ, ថ្លៃឈ្នួលចូលចត, ពន្ធនាំចូល, ពន្ធនាំចេញ និងថ្លៃសេវាសាធារណៈដទៃទៀតរួមទាំងថ្លៃឈ្នួលឃ្លាំង និងត្រូវធានាថាការបំពេញបែបបទគយត្រូវដំណើរការដោយគ្មានការយឺតយ៉ាវ ។

២- រាជរដ្ឋាភិបាលកម្ពុជាត្រូវធានាបង់ពន្ធ និងអាករជាបន្ទុករបស់រដ្ឋ នូវថ្លៃសេវាសាធារណៈទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាជំនួសឱ្យ GIZ ដែលពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងអនុវត្ត និងកិច្ចព្រមព្រៀងហិរញ្ញប្បទានដូចមានចែងក្នុងមាត្រា ២ នៃកិច្ចព្រមព្រៀងនេះ។

**មាត្រា ៤**

ក្នុងទិដ្ឋភាពដទៃទៀត ខ្លឹមសារទាំងឡាយនៃកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស ដែលបានចុះហត្ថលេខានាថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៩៤ ហើយដែលបានចែងក្នុងមាត្រា ១.១ ខាងលើ នឹងត្រូវយកមកអនុវត្តចំពោះកិច្ចព្រមព្រៀងនេះ ។

**មាត្រា ៥**

កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមីនា ឆ្នាំ ២០១៦ ជាភាសាខ្មែរ, អាល្លឺម៉ង់ និងអង់គ្លេស ។ អត្ថបទទាំង ៣ ភាសានេះមានតម្លៃដូចគ្នា ។ ក្នុងករណីមានការបកស្រាយមិនស្របគ្នារវាងអត្ថបទភាសាអាល្លឺម៉ង់ និងភាសាខ្មែរ នោះអត្ថបទភាសាអង់គ្លេស នឹងត្រូវទុកជាបានការ ។

**តំណាងរាជរដ្ឋាភិបាលកម្ពុជា**

[signature]

**គាត ឈន់**

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**អនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**តំណាងរដ្ឋាភិបាល**

**សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់**

[signature]

**Joachim Baron Marschall von Bieberstein**

**ឯកអគ្គរដ្ឋទូត**

**សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំកម្ពុជា**